សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៥៧៤ "ថ" ក្រ៦

ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៦០

ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ៣៦៣២

ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ ៥៣៣

ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## តាចនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការនៅថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ដោយមានសមាសភាពជំនុំជម្រះ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៦០ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **វ័ន្ត** ភេទប្រុស អាយុ៤៤ឆ្នាំ (កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៩) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៩ ទីកន្លែងកំណើតសង្កាត់ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះជួលលេខ ១១០ហ្សិត ផ្លូវលេខ២៦១ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ផល្លី "រ" ម្តាយឈ្មោះ [redacted] អង្គារព្រឹក "រ" ប្រពន្ធឈ្មោះ [redacted] ម៉ារីម៉ា "លែងលះ" មានកូន១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ៦០៣៦ "ញ" ដ.ព.ស ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨០៨៤ "ញ" ដ.ឃ.ដ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ (អ១)

ដីកាបង្គាប់រក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៧០១ "ញ"ដ.ឃ.ដ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរហាងកាហ្វេអាម៉ាហ្សូន (បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២-ឈ្មោះ [redacted] ហៀង ហៅ លីន** ភេទប្រុស អាយុ៣៤ឆ្នាំ (កើតថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៩) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ទីកន្លែងកំណើត [redacted] ខេត្តបាត់ដំបង ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ៥៦ ផ្លូវលេខ១៥បេ (បុរីពិភពថ្មីគួរស្រូវ៣) ភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សេង "ស" ម្តាយឈ្មោះ [redacted] ម៉ែងហួយ "ស" ប្រពន្ធឈ្មោះ [redacted] ម៉ាលីណែត មានកូនពីរនាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ៦០៣៥ "ញ" ដ.ព.ស ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ (ម១)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៨០៨៣ "ញ" ដ.ឃ.ដ ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២

ដីកាបង្គាប់រក្សាជនត្រូវចោទឱ្យនៅក្នុងឃុំបណ្តោះអាសន្នលេខ ៧០២ "ញ"ដ.ឃ.ដ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ៧៧១៥ "ញ"ដ.ព.ស ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទទាំងពីរ។

## អត្ថហេតុនៃរឿងអាងដូចតទៅ

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩និង៣០នាទី ដោយមានសេចក្តីរាយការណ៍ពីប្រជាពលរដ្ឋល្អថា មានការប្រព្រឹត្តបទល្មើសគ្រឿងញៀនខុសច្បាប់នៅម្តុំផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការសម្អាតប្រាក់ នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនបានចុះទៅពិនិត្យមើលនៅចំណុចគោលដៅ។ លុះដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១៣និង១០នាទី កម្លាំងសមត្ថកិច្ចបានចុះបង្ក្រាបនៅចំណុចក្បែរហាងការ៉ូអាម៉ាហ្សូន (បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនឈ្មោះ [redacted] វ័ន្ត រួមនឹងវត្ថុតាង ក្រាមពណ៌សថ្នាសង្ស័យជាសារធាតុញៀនប្រភេទកេតាមីនចំនួន៥កញ្ចប់ធំ មានទម្ងន់ប្រហែលកន្លះគីឡូក្រាមដាក់ក្នុងថង់ក្រដាសពណ៌ទឹកក្រូច និងបន្តនីតិវិធីត្រួតពិនិត្យឆែកឆេរនៅបន្តប់ជួលលេខ១១០ហ្សីត ផ្លូវលេខ២៦១ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ រកឃើញក្រាមពណ៌សថ្នា សង្ស័យជាសារធាតុញៀនប្រភេទកេតាមីនចំនួន៤កញ្ចប់ធំ ទម្ងន់ប្រហែល៣ខាំកន្លះ និងជញ្ជីងថ្លឹងគ្រឿងញៀន១គ្រឿង។ លុះដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ [redacted] វ័ន្ត បានសហការជាមួយសមត្ថកិច្ចឈានទៅដល់ការឃាត់ខ្លួនឈ្មោះ [redacted] ហៀង ហៅ លីន នៅចំណុចផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ រួមនឹងវត្ថុតាងក្រាមពណ៌សថ្នាសង្ស័យជាសារធាតុញៀនចំនួន១ដុំ (ទម្ងន់ប្រហែល១គីឡូក្រាម) ច្រកក្នុងថង់តែពណ៌បៃតង រួចបន្តនីតិវិធីឆែកឆេរនៅផ្ទះលេខ៥៦ ផ្លូវលេខ១៥B (បុរីពិភពថ្មីគួរស្រូវ៣) ភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ រកឃើញ

ជញ្ជីងថ្លឹងគ្រឿងញៀន១គ្រឿង។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថា គ្រឿងញៀនទាំងនោះគឺបានមកពីឈ្មោះ ម៉ាយ ភេទប្រុស អាយុ៣៧ឆ្នាំ ប្រើប្រាស់ទូរស័ព្ទលេខ ០៩៦ ៤៧៥ ៤៥៨៦។ ក្រោយពីធ្វើការសាកសួរ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួននិងដកហូតវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦៤១អ.ឃ.ទ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ២៦០អ.ឃ.ទ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤១៣"ញ"ដ.ដ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** បានឆ្លើយថា កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១រសៀល ខ្ញុំបានទូរស័ព្ទទៅឈ្មោះ ម៉ាយ តាមទូរស័ព្ទលេខ ០៩៦ ៤៧៥ ៤៥ ៨៦ ដើម្បីទិញគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់កន្លះគីឡូក្រាម ក្នុងតម្លៃ ៤.៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅលក់ឱ្យឈ្មោះ [redacted] វិញ ក្នុងតម្លៃ ៥.000 (ប្រាំពាន់) ដុល្លារអាមេរិក។ លុះមកដល់វេលាម៉ោងប្រហែល២រសៀលឈ្មោះ ម៉ាយ បានឱ្យមនុស្សប្រុសម្នាក់ (មិនស្គាល់ឈ្មោះ) យកគ្រឿងញៀនមកប្រគល់ឱ្យខ្ញុំនៅមុំផ្សារឈូណាយ ក្បែរផ្លូវ២៦១។ ពេលខ្ញុំបានទទួលគ្រឿងញៀនប្រភេទកេតាមីន រួចខ្ញុំបានហែកកញ្ចប់គ្រឿងញៀននោះ ឃើញមានគ្រឿងញៀនចំនួន៨កូនថង់ និងមានជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន១គ្រឿង។ ខ្ញុំបានសួរទៅឈ្មោះ ម៉ាយ ថាម្តេចបងឯងផ្ញើគ្រឿងញៀនមកឱ្យខ្ញុំលើសបីខាំ ហើយឈ្មោះ ម៉ាយ បានប្រាប់ឱ្យខ្ញុំថាយកគ្រឿងញៀនដែលសល់ចំនួន ៣ខាំងនោះទៅលាក់ទុកសិន។ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង១និង០០នាទីរសៀល ខ្ញុំយកគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់កន្លះគីឡូក្រាម ទៅលក់ឱ្យឈ្មោះ ចិន្តា ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ នៅមុំហាងការ៉ូអាម៉ាហ្សូន ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ហើយក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួន និងដកហូតវត្ថុតាងដែលជាគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់កន្លះគីឡូក្រាមពីខ្ញុំប្រាកដមែន។ បន្ទាប់ពីសមត្ថកិច្ចឃាត់ខ្លួន ហើយខ្ញុំបានសហការជាមួយសមត្ថកិច្ច ទៅយកគ្រឿងញៀនទម្ងន់ជាងបីខាំទៀតដែលខ្ញុំបានលាក់ទុកនៅបន្ទប់ជួល។ លុះមកដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ខ្ញុំបានសហការជាមួយសមត្ថកិច្ចដោយបានធ្វើតាមសមត្ថកិច្ចទាក់ទងទៅឈ្មោះ ម៉ាយ ដែលជាមេក្តោងលក់គ្រឿងញៀនឱ្យខ្ញុំ ដើម្បីទិញគ្រឿងញៀនបន្តែមតាមបញ្ជាសមត្ថកិច្ចរហូតដល់ការឃាត់ខ្លួនបក្ខពួកឈ្មោះ ម៉ាយ ម្នាក់ដែលជាអ្នកដឹកជញ្ជូនគ្រឿងញៀនមកឱ្យខ្ញុំ។ ខ្ញុំទើបតែជួញដូរគ្រឿងញៀនជាលើកទី១ ប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ហៀង ហៅ លីន ដែលសមត្ថកិច្ចឃាត់ខ្លួនមកនេះ ខ្ញុំមិនធ្លាប់ស្គាល់ពីមុនមកឡើយ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** ដែលឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, អយ្យការ និងចៅក្រមស៊ើបសួរ មានន័យប្រហាក់ប្រហែលគ្នាថា៖ នៅថ្ងៃមិនចាំ ខែមេសា ឆ្នាំ២០២២ ខ្ញុំបានដើរលេង និងចូលហូបអីនៅអាហារដ្ឋានជ្រៃធំ ម្តុំពេឡកុមារជាតិ ខណ្ឌឫស្សីកែវ ហើយបានស្គាល់ឈ្មោះ

ម៉ាយ អាយុប្រហែល៣៨ឆ្នាំ ជនជាតិខ្មែរ ប្រើប្រាស់ទូរស័ព្ទលេខ ០៩៦ ៤៧៥ ៤៥៨៦ តាមរយៈពួកម៉ាកណែនាំ ហើយបន្ទាប់ពីបានស្គាល់គ្នាមួយរយៈ ខ្ញុំនិងឈ្មោះ ម៉ាយ ព្រមទាំងមិត្តភក្តិផ្សេងទៀត បានទៅលេងគ្រឿងញៀនថ្នាំសប្បាយ (កេតាមីន) ជាញឹកញាប់នៅក្នុងបន្ទប់ជួលនៅម្តុំកោះពេជ្រ ចំពោះគ្រឿងញៀនថ្នាំសប្បាយនេះ គឺឈ្មោះ ម៉ាយ ជាអ្នករៀបចំឱ្យពួកខ្ញុំ។ ក្រោយមកខ្ញុំនិងឈ្មោះ ម៉ាយ បានស្គាល់គ្នាកាន់តែជិតស្និទ្ធ ហើយឈ្មោះ ម៉ាយ បានសួរខ្ញុំថា តើមានអ្នកណាត្រូវការថ្នាំញៀនថ្នាំសប្បាយទេ(កេតាមីន)? ជួយរកអ្នកទិញឱ្យផងចាំគាត់ឱ្យលុយចាយខ្លះ។ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ខ្ញុំបានស្គាល់ឈ្មោះ ចិន្តា ភេទប្រុស អាយុប្រហែល៣១ឆ្នាំ ជនជាតិខ្មែរ ប្រើទូរស័ព្ទលេខ ០៩៦ ៤៤៦ ៨៩៧៣ ត្រូវការថ្នាំញៀនថ្នាំសប្បាយ(កតាមីន) យកទៅឱ្យចិន ដោយគាត់ហ៊ានទិញគ្រឿងញៀនថ្នាំសប្បាយកន្លះគីឡូក្រាម តម្លៃ ៥.000$ (ប្រាំពាន់) ដុល្លារអាមេរិច ភ្លាមនោះ ខ្ញុំក៏បានទូរស័ព្ទទៅឈ្មោះ ម៉ាយ ថាឥឡូវមានគេត្រូវការគ្រឿងញៀនថ្នាំសប្បាយ(កេតាមីន) ចំនួនកន្លះគីឡូក្រាម ហើយគាត់បានឆ្លើយថា ឥឡូវគ្រឿងញៀនអស់ហើយ សូមឱ្យគេរង់ចាំប្រហែល០១សប្តាហ៍សិនទៅ ហើយគាត់បានសួរខ្ញុំវិញថា តើគេទិញគ្រឿងញៀនថ្នាំសប្បាយនេះគេប្រគល់លុយរបៀបមិច? ខ្ញុំបានប្រាប់គាត់វិញថា ពេលប្រគល់ឥវ៉ាន់គេប្រគល់លុយ គាត់និយាយទៀតថា អញ្ចឹងលក់ឱ្យគេកន្លះគីឡូក្រាមតម្លៃ ៥.000$ (ប្រាំពាន់) ដុល្លារអាមេរិក ផ្ញើរឱ្យគេ (ឈ្មោះ ម៉ាយ) ៤.៥00$ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិកបានហើយ។ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ ម៉ាយ បានទូរស័ព្ទមកខ្ញុំថា មានឥវ៉ាន់ហើយ(គ្រឿងញៀន) ចាំម៉ោងប្រហែល ១៤ មានគេដឹកយកមកឱ្យខ្ញុំ លុះប្រហែល១៥នាទីក្រោយ មានគេទូរស័ព្ទមកខ្ញុំថា បងឈ្មោះ ម៉ាយ យកឥវ៉ាន់ឱ្យ(គ្រឿងញៀន) ហើយសួរខ្ញុំចាំនៅកន្លែងណា ពេលនោះខ្ញុំបានប្រាប់គាត់វិញថា ប្អូនឯងយកមកឱ្យបងនៅម្តុំផ្សារឃ្លាំណែ ផ្លូវ២៦១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្រោយមកប្រហែល១៥នាទី មានបុរសខាងលើ បានទាក់ទងមកខ្ញុំម្តងទៀត និងបានជួបគ្នា រួចគាត់ក៏ប្រគល់ឥវ៉ាន់(គ្រឿងញៀន)មកឱ្យខ្ញុំ រួចគាត់ជិះម៉ូតូសង់១២៥ ពាក់មួកឃ្លុបពណ៌ខ្មៅចេញទៅបាត់ បន្ទាប់ពីបានទទួលឥវ៉ាន់ (គ្រឿងញៀន) ខ្ញុំក៏យកមកឆែកមើលឃើញមានសរសេរអក្សរថាចំនួន៨ខាំកន្លះ និងជញ្ជើងថ្លឹងគ្រឿងញៀន១គ្រឿង ពេលនោះខ្ញុំក៏បានទូរស័ព្ទសួរឈ្មោះ ម៉ាយ ថាបងយកគ្រឿងញៀនមកលើសហើយ គេត្រូវការតែកន្លះគីឡូទេ រួចគាត់តបវិញថា ថ្នាំញៀននៅសល់ទុកនៅខ្ញុំសិនទៅ។ ក្រោយពីបានទទួលថ្នាំញៀន ខ្ញុំក៏បានទូរស័ព្ទទៅឈ្មោះ ចិន្តា មានឥវ៉ាន់ហើយ(គ្រឿងញៀន) គាត់ក៏បានតបមកខ្លួនវិញថា ឥឡូវគាត់នៅខេត្តជាមួយពួកចិនចាំថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ គាត់ត្រលប់មកភ្នំពេញវិញ ចាំគាត់នឹងទាក់ទងមកខ្ញុំ។ លុះនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ នៅម៉ោងប្រហែល១២ ឈ្មោះ ចិន្តា បានទូរស័ព្ទមកខ្ញុំឱ្យយកគ្រឿងញៀនថ្នាំសប្បាយ (កេតាមីន) ចំនួនកន្លះគីឡូក្រាម នៅហាងកាហ្វេអាម៉ាហ្សូន(បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រោយពីជជែកគ្នារួច ខ្ញុំបានរៀបចំ និងជិះម៉ូតូកង់បីឥណ្ឌាដឹកយកគ្រឿងញៀនទៅប្រគល់ឱ្យឈ្មោះ ចិន្តា នៅហាងកាហ្វេអាម៉ាហ្សូន (បឹងកក់ ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ) ពេលទៅដល់ចំណុចខាងលើ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងចាប់យកវត្ថុតាង ក្រមពណ៌សចំនួន៥កញ្ចប់ សង្ស័យសារធាតុញៀន រួចបន្តនីតិវិធីទៅពិនិត្យឆែកឆេរផ្ទះជួលលេខ១១០ហ្សឹត ផ្លូវលេខ២០១ ក្រុមទី១៧ ភូមិ៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រកឃើញក្រមពណ៌ស ចំនួន៤កញ្ចប់ទៀត សង្ស័យជាសារធាតុញៀន និងជញ្ជើងថ្លឹងគ្រឿងញៀន១គ្រឿង បញ្ជូនមកកាន់មន្ទីរប្រឆាំងគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] ហៀង ហៅ លីន បានឆ្លើយថា កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង២រសៀល ខ្ញុំបានជិះម៉ូតូមកផ្សារដើមគរ ទិញវីតាមីនអាពីតុនទុកឱ្យកូននៅឱសថស្ថានបានហើយ ខ្ញុំក៏បានជិះម៉ូតូទៅរកមើលទិញគ្រឿងបាយសី និងទឹកអប់ទុកលក់ ស្រាប់តែឈ្មោះ ម៉ាយ បានទូរស័ព្ទមកខ្ញុំ ហើយសួរខ្ញុំថានៅណា? ខ្ញុំឆ្លើយថា ខ្ញុំកំពុងនៅផ្សារទួលទំពូង។ ភ្លាមនោះឈ្មោះ ម៉ាយ បានពឹងឱ្យខ្ញុំជួយទៅយកឥវ៉ាន់នៅផ្សារអូរឬស្សី (កន្លែងលក់ទាខ្ញែ) ទៅឱ្យភ្ញៀវនៅផ្សារឃ្លាយក្បែរសំណង់ដប់ពីរ ពេលនោះខ្ញុំបានសួរឈ្មោះ ម៉ាយ ថា ថ្លៃសេវាដឹកជញ្ជូន និងថ្លៃទំនិញឱ្យខ្ញុំយកពីភ្ញៀវនោះទេ ហើយឈ្មោះ ម៉ាយ បានប្រាប់ខ្ញុំថា គេគិតគូរឱ្យគាត់រួចអស់ហើយ គ្រាន់តែឱ្យខ្ញុំយកឥវ៉ាន់ឱ្យគេតាមលេខទូរស័ព្ទដែលគាត់ឱ្យបានហើយ។ បន្ទាប់មកខ្ញុំបានជិះម៉ូតូទៅយកឥវ៉ាន់នោះនៅផ្សារអូរឬស្សីរួច ហើយខ្ញុំបានដឹកឥវ៉ាន់នោះទៅឱ្យភ្ញៀវនៅផ្សារឃ្លាយបន្តទៀត។ ពេលទៅដល់ទីតាំងខ្ញុំបានទូរស័ព្ទទៅភ្ញៀវពីរលើកដែរ តែអត់លើក ភ្លាមៗនោះស្រាប់តែមានសមត្ថកិច្ច បានមកដល់ ហើយចាប់ខ្លួនបញ្ចូលក្នុងរថយន្ត ហើយខ្ញុំបានសួរសមត្ថកិច្ចថា ហេតុអ្វីបានពួកបងចាប់ខ្ញុំ? សមត្ថកិច្ចក៏បានប្រាប់ខ្ញុំថា ខ្ញុំដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ហើយសមត្ថកិច្ចបានហែកប្រអប់ឥវ៉ាន់នោះថតទុក និងប្រាប់ខ្ញុំថាប្រអប់ឥវ៉ាន់នោះគឺជាគ្រឿងញៀនប្រភេទកេតាមីន ពេលនោះខ្ញុំបានភ្ញាក់ផ្អើលតក់ស្លុតជាខ្លាំង ព្រោះខ្ញុំមិនទឹកស្មានថាឈ្មោះ ម៉ាយ បែរជាបោកប្រាស់ឱ្យខ្ញុំដឹកគ្រឿងញៀននោះឡើយ។ ភ្លាមៗនោះខ្ញុំបានព្យាយាមទូរស័ព្ទទៅលេខទូរស័ព្ទរបស់ឈ្មោះ ម៉ាយ ជាច្រើនលើក ប៉ុន្តែមិនអាចទាក់ទងបាន។ ដោយសារឈ្មោះ ម៉ាយ បានបិទលេខទូរស័ព្ទចោល។ ខ្ញុំពិតជាមិនដឹងថាកញ្ចប់ឥវ៉ាន់នោះជាគ្រឿងញៀនឡើយ។ ម្យ៉ាងទៀតខ្ញុំគិតថាប្រអប់ឥវ៉ាន់នោះគឺជាដុំ WIFI ព្រោះប្រអប់នោះជាប្រអប់ដាក់ដុំ WIFI ប៉ុណ្ណោះ ហើយឈ្មោះ ម៉ាយ ធ្លាប់ប្រាប់ខ្ញុំថា គាត់ជាអ្នកលក់អនឡាញ ទើបខ្ញុំជឿជាក់។ ខ្ញុំគិតថាកញ្ចប់ឥវ៉ាន់នោះមិនមែនកញ្ចប់ឥវ៉ាន់ខុសច្បាប់ ឬគ្រឿងញៀនឡើយ ព្រោះទីតាំងដែលខ្ញុំទៅយក និងដឹកឥវ៉ាន់ឱ្យគេនោះគឺជាផ្សារដែលមនុស្សច្រើនកុះករណាស់។ ខ្ញុំមិនចេះប្រើប្រាស់គ្រឿងញៀនឡើយ។ ហើយខ្ញុំក៏មិនធ្លាប់ឃើញគ្រឿងញៀនពីមុនមកឡើយ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ហៀង ហៅ លីន ដែលឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, អយ្យការ និងចៅក្រមស៊ើបសួរ មានន័យប្រហាក់ប្រហែលគ្នាថា៖ នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ ខ្ញុំបានស្គាល់បុរសម្នាក់ឈ្មោះ ម៉ាយ ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ជនជាតិខ្មែរ ប្រើប្រាស់ទូរស័ព្ទលេខ ០៩៦ ៤៧៥ ៤៥៨៦ តាមរយៈរកស៊ីឈើនៅតាមខេត្តជាមួយគ្នា ក្រោយមកកាលពីខែមីនា ឆ្នាំ២០២២ ខ្ញុំបានជួបឈ្មោះ ម៉ាយ ដោយចៃដន្យនៅអាហារដ្ឋានមួយកន្លែងមិនបានចាំឈ្មោះ នៅម្តុំទួលគោក និងមិត្តភក្តិផ្សេងទៀត ក្នុងអំឡុងពេលជួបគ្នា ខ្ញុំបានសួរឈ្មោះ ម៉ាយ ថាឥឡូវឯងរកស៊ីអី ចំណែកខ្ញុំរកស៊ីលក់បាយសី ហើយលក់មិនដាច់ដូចមុនទេ បើពួកម៉ាកឯងមានការងារធ្វើជួយណែនាំខ្ញុំផង។ ក្រោយមកឈ្មោះ ម៉ាយ បានបបួលខ្ញុំទៅញ៉ាំអីជាញឹកញាប់នៅអាហារដ្ឋាននានាក្នុងទីក្រុងភ្នំពេញ ដោយឈ្មោះ ម៉ាយ ជាអ្នកចេញលុយ និងឱ្យស្រុយខ្ញុំម្តងៗ ១00$ (មួយរយ) ដុល្លារអាមេរិកផងដែរ។ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ ម៉ាយ បានពឹងខ្ញុំជួយដឹកឥវ៉ាន់១កញ្ចប់ ទៅឱ្យគេនៅម្តុំផ្សារតូច ប៉ុន្តែខ្ញុំបានប្រាប់គាត់វិញថា សូមទោសពួកម៉ាក ខ្ញុំមិនបានជួយដឹកឥវ៉ាន់ឱ្យទេ ដោយសារខ្ញុំជាប់រវល់មើលកូនឈឺ រួចឈ្មោះ ម៉ាយ បានឆ្លើយតបវិញថា គ្រាន់តែពឹងជួយដឹកជញ្ជូន

ប៉ុណ្ណឹងអត់បាន ខ្ញុំបានតបវិញថា ពួកម៉ាកចាំលើកក្រោយចាំខ្ញុំជួយដឹក។ លុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ ម៉ាយ បានទូរសព្ទពីងខ្ញុំឱ្យជួយដឹកឥវ៉ាន់ឱ្យគេពីផ្សារអូរឬស្សីទៅផ្សារឃ្លូណ ផ្លូវ២៦១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ខ្ញុំសួរគាត់ថា ឥវ៉ាន់នឹងត្រូវដឹកឱ្យគេនៅម៉ោងប៉ុន្មាន? គាត់បានឆ្លើយតបមកខ្ញុំវិញថា មកយកឥវ៉ាន់ឱ្យគេនៅម៉ោង១៧ បន្ទាប់ពីបាននិយាយគ្នារួចនៅម៉ោងប្រហែល១៧ ខ្ញុំបានជិះម៉ូតូទៅដល់ផ្សារអូរឬស្សី រួចបានទូរសព្ទទៅឈ្មោះ ម៉ាយ ថាខ្ញុំបានមកដល់ផ្សារអូរឬស្សី ហើយពួកម៉ាកនៅណា គាត់ក៏បានឆ្លើយតបវិញថាឱ្យខ្ញុំជិះម៉ូតូមកខាងជើងផ្សារអូរឬស្សីជិតកន្លែងលក់ជ្រកខែ ពេលខ្ញុំជិះទៅដល់កន្លែងគាត់ប្រាប់ គាត់ក៏បានប្រគល់ថង់ក្រដាស់ពណ៌ផ្ទៃមេឃ (មានប្រអប់ក្រដាស់រូបវ៉ាយហ្វាយ) ទៅប្រគល់ឱ្យគេនៅមុំផ្សារឃ្លូណ ផ្លូវ២៦១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក តាមលេខទូរស័ព្ទ ០៩៦ ៧៦៩ ៧៦៥០។ ក្រោយពេលខ្ញុំបានយកឥវ៉ាន់ពីឈ្មោះ ម៉ាយ ដាក់លើម៉ូតូរួច ខ្ញុំបានជិះម៉ូតូទៅផ្សារឃ្លូណ ហើយខ្ញុំបានទូរសព្ទទៅលេខ ០៩៦៧ ៦៩៧ ៦៥០ មកទទួលឥវ៉ាន់ ក៏ឃើញមានសមត្ថកិច្ចមួយក្រុមហៅសាកសួរឆែកឆេរកឃើញ ក្រោមពណ៌ស១ដុំច្រកក្នុងស្បោងបៃតងទម្ងន់ប្រហែល១គីឡូក្រាម សង្ស័យសារធាតុញៀន រួចសមត្ថកិច្ចបានឃាត់ខ្លួន នៅម៉ោង១៧និង៤៦នាទី ចំណុចមុំផ្សារឃ្លូណ ផ្លូវ២៦១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ទើបខ្ញុំដឹងថាឥវ៉ាន់នេះជាគ្រឿងញៀន និងសមត្ថកិច្ចបន្តនីតិវិធីត្រួតពិនិត្យឆែកឆេរផ្ទះរបស់ខ្ញុំលេខ៥៦ ផ្លូវលេខ១៥B (បុរីពិភពថ្មីគួរស្រូវ៣) ភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ បានរកឃើញ ជញ្ជីង០១គ្រឿង ដែលឈ្មោះ ម៉ាយ បានផ្ញើនៅខ្ញុំប្រហែលកន្លះឆ្នាំមកហើយ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួន រួចបញ្ជូនខ្ញុំមកមន្ទីរគ្រឿងញៀនតែម្តង។

-ក្រឡាបញ្ជីលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៣៨៨៤៩/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ជាលទ្ធផល៖

សំណាកទី១៖ វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ កេតាមីន (Ketamine) បរិមាណសារធាតុ កេតាមីន គិតជាភាគរយនៃទម្ងន់ គឺ៖ ៦០.១០% (ហុកសិប កណ្តាក់សញ្ញា ដប់ ភាគរយ)។

សំណាកទី២៖ វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ កេតាមីន (Ketamine) បរិមាណសារធាតុ កេតាមីន គិតជាភាគរយនៃទម្ងន់ គឺ៖ ៦០.១០% (ហុកសិប កណ្តាក់សញ្ញា ដប់ ភាគរយ)។

-ក្រឡាបញ្ជីលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៣៨៨៥០/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ជាលទ្ធផល៖ វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ កេតាមីន (Ketamine) បរិមាណសារធាតុ កេតាមីន គិតជាភាគរយនៃទម្ងន់ គឺ៖ ៦០.១០% (ហុកសិប កណ្តាក់សញ្ញា ដប់ ភាគរយ) ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមការសួរដេញដោល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] វ័ន្ត និងជនជាប់ចោទឈ្មោះ [redacted] ហៀង ហៅ លីន ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ២៦០អ.ឃ.ទ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## មេធាវីការពារសិទ្ធិជនជាប់ចោទ

កូនក្តីខ្ញុំបាទឈ្មោះ [redacted] វ័ន្ត បានធ្វើយសារភាពដោយស្មោះត្រង់ កូនក្តីខ្ញុំបាទមានជីវភាពខ្វះខាត ទើបលង់ក្នុងការលួងលោមជនឆបោក សុំបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

កូនក្តីខ្ញុំបាទឈ្មោះ [redacted] ហៀង ហៅ លីន មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយកូនក្តីខ្ញុំបាទចាញ់បោកគេ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] វ័ន្ត បានស្នើសុំតុលាការថា សូមបន្ធូរបន្ថយទោសដល់រូបខ្ញុំផង។

ជនជាប់ចោទឈ្មោះ [redacted] ហៀង ហៅ លីន បានស្នើសុំតុលាការថា សូមលើកលែងទោសដល់រូបខ្ញុំផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងរាជធានីភ្នំពេញ
## យល់ឃើញថា

១-ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** មកជំនុំជម្រះពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរហាងការ៉ូអាម៉ាហ្សូន (បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ និងជនជាប់ចោទឈ្មោះ [redacted] ហៀង ហៅ លីន មកជំនុំជម្រះពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ តុលាការអាចយករឿងនេះ មកជំនុំជម្រះតាមមាត្រា ២០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា ជនជាប់ចោទពិតជាបានប្រព្រឹត្ត ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។ ហេតុដូច្នេះ តំណាងអយ្យការសុំរក្សាការចោទប្រកាន់ និងតម្កល់ដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការទុកជាបានការដដែល និងប្តឹងសុំចៅក្រមជំនុំជម្រះ ពិចារណាផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។ ចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ គឺមានភាពសមស្រប ដែលតុលាការអាចយកមកពិនិត្យ និងសម្រេចតាមផ្លូវច្បាប់បាន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** ថា ខ្លួនបានទូរសព្ទទៅឈ្មោះ ម៉ាយ ដើម្បីទិញគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់កន្លះគីឡូក្រាម ក្នុងតម្លៃ ៤,៥០០$ (ប្លនពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅលក់ឱ្យឈ្មោះ ចិន្តា ក្នុងតម្លៃ ៥,០០០$ (ប្រាំពាន់) ដុល្លារអាមេរិក។ ឈ្មោះ ម៉ាយ បានឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះ យកគ្រឿងញៀនមកឱ្យខ្លួននៅម្តុំផ្សារឃ្លាំងណាយ ក្បែរផ្លូវ២៦១។ ពេលខ្លួនបានគ្រឿងញៀនហើយ ខ្លួនបានហែកកញ្ចប់គ្រឿងញៀននោះ ឃើញមានគ្រឿងញៀន៨កូនចង់ និងជញ្ជីងសម្រាប់ថ្លឹង១គ្រឿង។ ខ្លួនបានសួរទៅឈ្មោះ ម៉ាយ ថា ម្តេចបងឯងផ្ញើគ្រឿងញៀនមកខ្លួនលើសបីខាំ ហើយឈ្មោះ ម៉ាយ បានឱ្យខ្លួនយកគ្រឿងញៀននៅលាក់ទុកសិន។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនបានយកគ្រឿងញៀនទម្ងន់កន្លះគីឡូក្រាមទៅលក់ឱ្យឈ្មោះ ចិន្តា នៅម្តុំហាងកាហ្វេអាម៉ាហ្សូន ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** មានភាពសកម្មក្នុងការជួញដូរគ្រឿងញៀន ទើបអាចស្គាល់ម៉ូយទិញគ្រឿងញៀន និងជួញដូរគ្រឿងញៀនបាន។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន** ថា ឈ្មោះ ម៉ាយ បានពឹងខ្លួនជួយទៅយកឥវ៉ាន់នៅផ្សារអូរឬស្សី (កន្លែងលក់ទាខ្វៃ) ទៅឱ្យភ្ញៀវនៅផ្សារឃ្លាំងណាយក្បែរសំណង់ដប់ពីរ ឈ្មោះ ម៉ាយ ថា ផ្តែសេរាដឹកជញ្ជូន និងផ្តែទំនិញឱ្យខ្លួនយកពីភ្ញៀវនោះទេ ហើយឈ្មោះ ម៉ាយ បានប្រាប់ខ្លួនថា គេគិតគូរឱ្យគាត់រួចអស់ហើយ គ្រាន់តែឱ្យខ្លួនយកឥវ៉ាន់ឱ្យគេតាមលេខទូរសព្ទដែលគាត់ឱ្យបានហើយ។ បន្ទាប់មកខ្លួនបានជិះម៉ូតូទៅយកឥវ៉ាន់នោះនៅផ្សារអូរឬស្សីរួច ហើយខ្លួនបានដឹកឥវ៉ាន់នោះទៅឱ្យភ្ញៀវនៅផ្សារឃ្លាំងណាយបន្តទៀត។ ពេលទៅដល់ទីតាំងខ្លួនបានទូរសព្ទទៅភ្ញៀវពីរលើកដែរ តែអត់លើក ភ្លាមៗនោះស្រាប់តែមានសមត្ថកិច្ច បានមកដល់ ហើយចាប់ខ្លួនបញ្ជូលក្នុងរថយន្តតែម្តង។ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន** ទើបតែប្រព្រឹត្តលើកទី១ ពុំមែនជាសកម្មភាពដែលខ្លួនធ្លាប់ប្រព្រឹត្តនោះទេ ទើបសមត្ថកិច្ចឃាត់ខ្លួនបាន។ ប៉ុន្តែចម្លើយបដិសេធថា ខ្លួនពុំបានដឹងថាក្នុងប្រអប់នោះជាថ្នាំញៀន គ្រាន់តែជាចម្លើយដោះសារដើម្បីគេចវេះពីការទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ។ ចម្លើយបដិសេធរបស់ជនជាប់ចោទគ្មានមូលដ្ឋានត្រឹមត្រូវសម្រាប់តុលាការពិចារណា ដើម្បីដោះបន្ទុកឡើយ គឺមានតែភស្តុតាងដាក់បន្ទុកចំពោះអំពើដែលជនជាប់ចោទបានប្រព្រឹត្ត គឺវត្ថុតាងជាគ្រឿងញៀន និងជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀន ដែលដកហូតបានពីជនជាប់ចោទ អាចឱ្យសន្និដ្ឋានបានថា ជនជាប់ចោទពិតជាបានទិញលក់ថ្នាំញៀនពិតប្រាកដមែន។

៥-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** និងឈ្មោះ [redacted] **ហៀង ហៅ លីន** មានភាពស្របគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលចម្លើយសារភាពនេះមិនស្ថិតក្រោមរូបភាពនៃការបង្ខិតបង្ខំណាមួយឡើយ ដូច្នេះវាមានតម្លៃជាភស្តុតាងសម្រាប់តុលាការពិចារណា។ សក្ខីកម្មរបស់ជនជាប់ចោទស៊ីសង្វាក់ទៅនឹងភស្តុតាងជា ថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទ ដែលអាចឱ្យតុលាការកំណត់បានថា ជននេះពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។

៦-យោងតាមមាត្រា៤៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងថា "ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយ

ខុសច្បាប់នូវសារធាតុញៀន" និងត្រូវផ្តន្ទាទោសតាមមាត្រា៤៨ កថាខណ្ឌទី៦ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល។ ដូចនេះថ្នាំញៀនដកហូតបានពីជនជាប់ចោទមានទម្ងន់ ១៨៤១,៩០ក្រាម អាចឱ្យតុលាការកំណត់បានពីបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤៨ កថាខណ្ឌទី ៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២។

៧-តាមលទ្ធផលកោសល្យវិច័យលេខ៣៨៨៤៩/២២ ម.ព.អ.ជ.ប.ក.ញ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២២ បញ្ជាក់ពីលទ្ធផល៖

+សំណាកទី១ វិជ្ជមាន ដែលមានបរិមាណកេតាមីន ចំនួន ៤៩៩,៣៣ក្រាម X ៦០,១០ / 100 = ៣០០,០៩ក្រាម ដូចនេះនាំឱ្យកម្រិតភាពសុទ្ធនៃទម្ងន់សរុបស្មើ ៣០០,០៩ក្រាម ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ និងត្រូវផ្តន្ទាទោសតាមមាត្រា៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

+សំណាកទី២ វិជ្ជមាន ដែលមានបរិមាណកេតាមីន ចំនួន ៣៤២,២៩ក្រាម X ៦០,១០ / 100 = ២០៥,៧១ក្រាម ដូចនេះនាំឱ្យកម្រិតភាពសុទ្ធនៃទម្ងន់សរុបស្មើ ២០៥,៧១ក្រាម ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ និងត្រូវផ្តន្ទាទោសតាមមាត្រា៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-តាមលទ្ធផលកោសល្យវិច័យលេខ៣៨៨៥០/២២ ម.ព.អ.ជ.ប.ក.ញ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២២ បញ្ជាក់ពីលទ្ធផល វិជ្ជមាន ដែលមានបរិមាណមេតំហ្វេតាមីន ចំនួន ៩៩៩,៦៤ក្រាម X ៦០,១០ / 100 = ៦០០,៧៨ក្រាម ដូចនេះនាំឱ្យកម្រិតភាពសុទ្ធនៃទម្ងន់សរុបស្មើ ៦០០,៧៨ក្រាម ស្ថិតនៅក្នុងតារាងទី២ មាត្រា ៥ និងត្រូវផ្តន្ទាទោសតាមមាត្រា៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-ជនជាប់ចោទឈ្មោះ [redacted]**វ័ន្ត** និងជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន** ជាសមត្ថជនដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជននេះមានបញ្ហាខាងស្មារតីឡើយ នាពេលកំពុងប្រព្រឹត្តបទល្មើស ដូចនេះជនជាប់ចោទពិតជាមានស្មារតីធម្មតាក្នុងពេលប្រព្រឹត្តបទល្មើស និងអាចយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន។

១០-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ **ម៉ាន់ វ័ន្ត** ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរហាងកាហ្វេអាម៉ាហ្សូន (បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ និងជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន** ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពអ្នកដទៃ គ្រោះថ្នាក់ចំពោះអាយុជីវិត ស្មារតី និងអនាគតរបស់អ្នកប្រើប្រាស់គ្រឿងញៀន។ ទន្ទឹមនឹងនេះអំពើរបស់ជនជាប់ចោទ ការធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងបន្ទុកសង្គមធ្ងន់ធ្ងរ ដោយសារកើនឡើងនៃអ្នកប្រើប្រាស់គ្រឿងញៀន។

១២-វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ១៨៦៧ រ.វ.ត ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ រួមមាន៖

+គ្រឿងញៀនទម្ងន់ ១៨៤១,៩០ក្រាម ដកហូតពីជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** និងជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន**, ទូរស័ព្ទដៃម៉ាក OPPO ពណ៌ខ្មៅ ចំនួន១គ្រឿង គុណភាពចាស់ មិនដំណើរការ, អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំនួន១សន្លឹក, ម៉ូតូម៉ាក YAMAKA TTX ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1DC-1363 ចំនួន១គ្រឿង (មិនប្រក្រតី) និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន១គ្រឿង ដកហូតពីជនជាប់ចោទឈ្មោះ [redacted] **ហៀង ហៅ លីន** និងទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ខៀវទឹកប៊ិច ចំនួន១គ្រឿង គុណភាពចាស់ មិនដំណើរការ, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន១គ្រឿង ដកហូតពីជនជាប់ចោទឈ្មោះ [redacted] **វ័ន្ត** គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

## ហេតុផ្លូវច្បេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] **វ័ន្ត** ភេទប្រុស អាយុ៤៤ឆ្នាំ (កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៩) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២៨ (ម្ភៃប្រាំបី) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ៧០.000.000 (ចិតសិបលាន) រៀល។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្បែរហាងការ៉ូអាម៉ាហ្សូន (បឹងកក់) ផ្លូវR6 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ឈ្មោះ [redacted] **ហៀង ហៅ លីន** ភេទប្រុស **អាយុ៣៤ឆ្នាំ** (កើតថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៩) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **២៦ (ម្ភៃប្រាំមួយ) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ៤០.000.000 (សែសិបលាន) រៀល។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ២៦១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៨ កថាខណ្ឌទី៣ និងកថាខណ្ឌទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-រឹបអូសវត្ថុចាប់យកមាន៖ គ្រឿងញៀនទម្ងន់ ១៨៤១,៩០ក្រាម, ទូរស័ព្ទដៃម៉ាក OPPO ពណ៌ខ្មៅ ចំនួន ១គ្រឿង, អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ចំនួន១សន្លឹក, ម៉ូតូម៉ាក YAMAKA TTX ពណ៌ខ្មៅ ផ្លាកលេខ ភ្នំពេញ 1DC-1363 ចំនួន១គ្រឿង, ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន១គ្រឿង, ទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ខៀវទឹកប៊ិច ចំនួន១គ្រឿង, និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន ចំនួន១គ្រឿង តាមមាត្រា៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៩៣ មាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងពីរ មេធាវីការពារ សិទ្ធិជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ | ហត្ថលេខា និងត្រា៖ |
| [redacted] | | | |

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។"

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner